# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាទិវានៃការត្រាស់ហៅនៅភ្នំពេញថ្មី
# ថ្ងៃទី០៧ ឧសភា ២០១៧

អត្ថបទទី១៖ កក ២,១៤ក.៣៦-៤១
អត្ថបទទី២៖ សល ២,២០ខ-២៥
ដំណឹងល្អ៖ យហ ១០,១-១០

បងប្អូនជាទីស្រឡាញ់!

ជួនកាលយើងគិតថា ព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា ជាព្រះសហគមន៍មាន ដោយសារមានបូជាចារ្យ បងប្រុសបងស្រីច្រើនណាស់ បើធៀបជាមួយចំនួនគ្រីស្តបរិស័ទដែលមាននៅក្នុងប្រទេសយើង។ ក៏ប៉ុន្តែបូជាចារ្យខ្មែរមានតែ៩នាក់ ក្រៅពីនោះសុទ្ធតែជាសាសនទូតមកពីបរទេស ដែលនៅមួយរយៈត្រូវត្រលប់ទៅវិញ ដើម្បីរៀនបន្តដើម្បីទីបម្រើកន្លែងផ្សេងជាដើម។ ពេលខ្ញុំប្រជុំជាមួយលោកបូជាចារ្យខ្មែរទាំង៩នាក់ លោកបានសួរខ្ញុំថា **"តើលោកអភិបាលទន្ទឹងរងចាំអ្វីខ្លះពីយើង?"** ខ្ញុំបានឆ្លើយថា **"ខ្ញុំទន្ទឹងរងចាំឲ្យជួយកសាងព្រះសហគមន៍ខ្មែរ ដែលចាក់ឫសយ៉ាងជ្រៅនៅលើទឹកដីនេះ"**។ តាមពិតយើងមិនមានគ្នាច្រើនទេ យើងធ្វើដូចម្តេចដើម្បីឲ្យព្រះសហគមន៍របស់យើងចាក់ឫសយ៉ាងជ្រៅនៅលើទឹកដីយើង។ ថ្ងៃនេះជាឱកាសមួយ ដើម្បីឲ្យយើងភ្ញាក់ស្មារតី ដើម្បីឲ្យយើងគិត **តើព្រះជាម្ចាស់ទន្ទឹងរងចាំអ្វីខ្លះពីខ្ញុំ?**។ ពេលព្រះយេស៊ូបានទេសនាលើកទីមួយនៅធម្មសាលាកាផានុមហើយ មហាជនទាំងអស់ដែលកំពុងស្តាប់គេសម្លឹងមើលព្រះយេស៊ូ ដូចគ្នាដែរយប់មិញពេលយើងបានអធិដ្ឋាននៅទីនេះ នៅពេលនោះយើងដូចជាបានសម្លឹងមើលព្រះយេស៊ូដែរ។ សម្លឹងមើលព្រះយេស៊ូ ដើម្បីស្តាប់ព្រះសូរសៀងរបស់ព្រះអង្គ ដើម្បីចូលនៅក្នុងទំនាក់ទំនងយ៉ាងជ្រៅជាមួយព្រះយេស៊ូ ដោយសារព្រះយេស៊ូបានធ្វើដំណើរជាមួយយើង ពីថ្ងៃដែលយើងទទួលការត្រាស់លើកដំបូង ឲ្យស្រឡាញ់ព្រះអង្គនិងដើរតាមព្រះអង្គ។ នៅពេលយើងស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូលើកទីមួយ នៅពេលនោះយើងចាប់ផ្តើមស្គាល់ព្រះយេស៊ូខ្លះៗ។ អធិដ្ឋានផង ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ផង ទទួលអគ្គសញ្ញាលើកលែងទោសផង នេះបន្តិចម្តងៗណែនាំឲ្យយើងចូលនៅក្នុងទំនាក់ទំនងជាមួយព្រះយេស៊ូដែលជាមិត្តសម្លាញ់របស់យើង។ ដូចសន្តបុព្វាល់ឌីហ្វូហ្គូ បានធ្វើដំណើរជាមួយព្រះយេស៊ូ និងព្រះយេស៊ូបានអោបគាត់ហើយធ្វើដំណើរជាមួយគាត់យ៉ាងជិតស្និត។

ជីវិតរបស់យើង ធ្វើដូចម្ដេចដើម្បីស្គាល់ព្រះយេស៊ូថែមទៀត? ខ្ញុំសង្ឃឹមថាបងប្អូននឹងមានឱកាសច្រើនដើម្បីស្គាល់ព្រះអង្គ។ ស្គាល់ព្រះយេស៊ូថែមទៀត ដើម្បីនឹកឃើញគ្រប់ពេលវេលា ពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹក ដំបូងយើងទទួលទឹកលើក្បាល ក្រោយមកយើងទទួលប្រេង បន្ទាប់មកយើងទទួលអាវសមានអត្ថន័យខ្លាំងណាស់ ព្រោះចាប់ពីពេលនេះតទៅយើងបំពាក់ព្រះយេស៊ូ យើងមិនអាចយកព្រះយេស៊ូចេញពីយើងបានទេ ព្រះអង្គបីដូចជាស្បែករបស់យើង។ ពីថ្ងៃដែលយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក ដូចយើងបានប្រថាប់ត្រាមួយដែលមិនអាចលប់ជ្រះ នេះជាព្រះយេស៊ូដែលធ្វើដំណើរជាមួយយើង ពីពេលនោះមកយើងភ្ជាប់ជាមួយព្រះយេស៊ូ។ យើងជាគ្រីស្តបរិស័ទ ជាបរិស័ទរបស់ព្រះគ្រីស្ត ទោះបីយើងភ្លេចព្រះយេស៊ូ ទោះបីយើងនៅឆ្ងាយពីព្រះយេស៊ូ ក៏ព្រះយេស៊ូនៅជាមួយយើងដដែល។ ពេលយើងបង្កើតទំនាក់ទំនងបន្តិចម្ដងៗជាមួយព្រះយេស៊ូ យើងអាចយល់ថាពិតមែនខ្ញុំជាសាវ័ករបស់ព្រះគ្រីស្ត ខ្ញុំជាមិត្តសម្លាញ់របស់ព្រះអង្គដែលភ្ជាប់ជាមួយព្រះយេស៊ូយ៉ាងជិតស្និត។ ណែនាំឲ្យយើងគិតបន្តិចម្ដងៗ ខ្ញុំស្គាល់ព្រះយេស៊ូហើយ ហេតុនេះហើយទំនាក់ទំនងយ៉ាងជិតស្និតជាមួយព្រះយេស៊ូ ណែនាំឲ្យយើងគិតពិចារណាអំពីជីវិតយើង។ យើងជាមិត្តសម្លាញ់របស់ព្រះយេស៊ូ យើងធ្វើអ្វីខ្លះដើម្បីឲ្យមិត្តភាពរបស់យើងជាមួយព្រះអង្គ ទៅជាសក្ខីភាពសម្រាប់បងប្អូនឯទៀតៗ។ ខ្ញុំធ្វើយ៉ាងណាដើម្បីដើរតាមព្រះយេស៊ូតែម្ដង? ព្រះយេស៊ូជាគ្រូគង្វាលដ៏សប្បុរស ណែនាំឲ្យយើងឆ្លើយទៅព្រះអង្គបាទ! ចាស*! ខ្ញុំចង់ធ្វើដំណើរជាមួយព្រះយេស៊ូជានិច្ច។ ដូចព្រះនាងម៉ារី ដែលបានឆ្លើយថានាងខ្ញុំជាអ្នកបម្រើសូមបានសម្រេចតាមពាក្យរបស់លោកចុះ។ ដូចលោកយ៉ូសែប ដែលជាស្វាមីរបស់ព្រះនាងម៉ារី ដែលបានឆ្លើយថា បាទខ្ញុំទទួលនាងម៉ារីជាភរិយារបស់ខ្ញុំដោយសារព្រះអង្គបានជ្រើសរើសឲ្យខ្ញុំ។ មរណសាក្សីនៅប្រទេសកម្ពុជា យើងមានទាំងលោកអភិបាល លោកបូជាចារ្យ បងប្រុសបងស្រី និងគ្រីស្តបរិស័ទធម្មតា ដែលបានស្លាប់ ពួកគាត់ទាំងអស់មិនមែនជាមនុស្សពិសេស គេមិនបានសម្រេចចិត្តពីដើមថាយើងស្លាប់សម្រាប់ព្រះជាម្ចាស់ គេចង់រស់នៅដើម្បីបម្រើព្រះសហគមន៍។ ប៉ុន្តែនៅក្នុងកាលៈទេសៈនៃប្រវត្តិសាស្រ្តណែនាំឲ្យគេស្លាប់ដើម្បីផ្ដល់សក្ខីភាពឲ្យយើង។ ពួកគាត់បានឆ្លើយពីដើមរៀងមកថា បាទ! ចាស*! ខ្ញុំចង់ធ្វើដំណើរជាមួយព្រះយេស៊ូជានិច្ច ខ្ញុំចង់ភ្ជាប់ជាមួយព្រះយេស៊ូ ដោយសារព្រះយេស៊ូណែនាំឲ្យខ្ញុំមានអំណរសប្បាយពិតប្រាកដ។ ថ្ងៃនេះយើងឃើញរបៀបព្រះ

យេស៊ូដែលជាគ្រូគង្វាលដ៏សប្បុរស ចៀមជាសត្វមួយដែលស្គាល់គ្រូគង្វាលរបស់វាយ៉ាងច្បាស់។ នៅអ៊ីស្រាអែលពេលយប់ អ្នកគង្វាលសត្វចៀមទាំងអស់បានប្រមូលចៀមរបស់គេមកក្នុងហ្វូងតែមួយ ដើម្បីនៅក្បែរៗគ្នាជួយការពារកុំឲ្យមានចោរលួច កុំឲ្យមានចចកមកស៊ីចៀមរបស់គេ។ ព្រឹកឡើង គេបែកគ្នាហើយអ្នកគង្វាលនីមួយៗគេមានសម្លេងពិសេសមួយដើម្បីហៅចៀមរបស់ខ្លួនឲ្យមកតាម ហើយចៀមនោះវាស្គាល់សម្លេងរបស់ម្ចាស់វាភ្លាម។ នេះជាមូលហេតុ ពេលព្រះយេស៊ូនិយាយអំពីពាក្យប្រស្នានេះមានន័យណាស់ ដោយសារព្រះយេស៊ូដ៏មានសម្លេងពិសេសមួយ ដើម្បីហៅយើងឲ្យដើរតាមព្រះអង្គដែរ។ ព្រះយេស៊ូបានបើកទ្វារឲ្យចៀមចូល ហើយឲ្យចៀមទាំងអស់ស្តាប់សម្លេងរបស់ព្រះអង្គ ដូច្នេះពេលព្រះយេស៊ូហៅយើង យើងមិនអាចច្រឡំបានទេ យើងមិនអាចដើរតាមព្យាករីផ្សេងៗបានឡើយ យើងមានតែព្រះយេស៊ូមួយព្រះអង្គគត់ដែលយើងត្រូវដើរតាម។ ចៀមស្គាល់សម្លេងព្រះយេស៊ូយ៉ាងច្បាស់ ហើយព្រះអង្គក៏ស្គាល់សម្លេងចៀមរបស់ព្រះអង្គដែរ គាត់បានហៅចៀមរបស់គាត់តាមឈ្មោះរបស់វារៀងៗខ្លួនៗ ក្រោយមកនាំចេញទៅខាងក្រៅ។ ជីវិតជាមួយព្រះយេស៊ូ គឺព្រះអង្គណែនាំឲ្យយើងចេញដើម្បីប្រកាសអំណរសប្បាយដែលយើងបានទទួលជាមួយព្រះយេស៊ូ។ នៅក្នុងព្រះសហគមន៍កម្ពុជា ជាកន្លែងមួយពិសេសដែលណែនាំឲ្យយើងអនុវត្តព្រះបន្ទូលនេះ។ ពេលខ្ញុំចាប់ផ្តើមបេសកកម្មជាមួយលោកលី នៅឆ្នាំ ២០០១ យើងមានគ្រីស្តបរិស័ទតែម្នាក់គត់ រហូតមកដល់សព្វថ្ងៃយើងមានប្រហែល៥០០នាក់ហើយ។ នេះដោយសារយើងចេញទៅប្រកាសដំណឹងល្អពីភូមិមួយទៅភូមិមួយ ពីចំការទៀងទៅគិរីវង់ ពីគិរីវង់នៅកោះស្លា ពីកោះស្លាទៅសន្តប៉ូល ពីសន្តប៉ូលទៅព្រៃកប្បាស់ ពីព្រៃកប្បាស់ទៅត្រពាំងក្រញូង ពីត្រពាំងក្រញូងទៅកំពង់អំពិល ពីកំពង់អំពិលទៅទីរួមខេត្តតាកែវ។ តាមកន្លែងនីមួយៗ យើងត្រូវការចេញយើងមិនអាចជាប់នៅកន្លែងមួយ ផ្ទុយទៅវិញព្រះយេស៊ូណែនាំឲ្យយើងចេញទៅខាងក្រៅ។ ជួនកាលមនុស្សយើងភ័យ យើងខ្លាចទៅជួបមនុស្សថ្មី ទីកន្លែងថ្មី យើងភ័យខ្លាចទៅបង្កើតទំនាក់ទំនងជាមួយមនុស្សដែលយើងមិនដែលស្គាល់សោះ ប៉ុន្តែ **លុះគាត់បញ្ចេញចៀមចេញពីក្រោលអស់ហើយ គាត់ដើរនាំមុខវា ហើយវាដើរតាមក្រោយគាត់ព្រោះវាស្តាប់សម្លេងគាត់។** យើងមានព្រះយេស៊ូនៅខាងមុខ ព្រះយេស៊ូធ្វើដំណើរជាមួយយើង ព្រះអង្គនៅជាមួយយើង យើងមិនត្រូវខ្លាចអ្វីទេ ព្រោះព្រះអង្គជួនកាលនៅខាងមុខ ជួនកាលនៅកណ្តាល ជួនកាលនៅខាងក្រោយដើម្បីជំរុញឲ្យយើងទៅ។ យើងត្រូវការគិតអំពីជីវិតរបស់យើង យើងធ្វើដូចម្តេចដើម្បីឲ្យជីវិតរបស់

យើងជាគ្រីស្តបរិស័ទ ជាមិត្តសម្លាញ់របស់ព្រះយេស៊ូ ចេញពីកន្លែងផ្ទាល់ខ្លួនទៅផ្តាល់សក្ខីភាពដើម្បីណែនាំឲ្យមនុស្សផ្សេងៗ អាចទទួលសំណាសប្បាយនៃដំណឹងល្អ ដោយដឹងថា **"ខ្ញុំមកដើម្បីឲ្យមនុស្សលោកមានជីវិត ហើយឲ្យគេមានជីវិតពេញបរិបូរណ៍"។** ទោះបីព្រះសហគមន៍របស់យើងតូចក៏ដោយ យើងខិតខំរស់នៅក្នុងអំណរសប្បាយ ដោយសារយើងដឹងថាព្រះយេស៊ូចង់ឲ្យយើងមានជីវិតយ៉ាងបរិបូរណ៍។ ថ្ងៃនេះយើងបន្តអធិដ្ឋាន ដោយសួរខ្លួនឯងថា **តើខ្ញុំអាចធ្វើដូចម្តេច ដើម្បីបម្រើបងប្អូនឯទៀតៗ ឲ្យគេបានទទួលជីវិតពីព្រះយេស៊ូ? តើខ្ញុំធ្វើដូចម្តេច ដើម្បីឲ្យសេចក្តីស្រឡាញ់របស់ព្រះយេស៊ូដែលខ្ញុំបានទទួលនៅក្នុងជីវិតរបស់ខ្ញុំ អាចទៅជាសេចក្តីស្រឡាញ់មួយពិសេសសម្រាប់បងប្អូនឯទៀតៗដែរ? តើខ្ញុំធ្វើដូចម្តេច ដើម្បីឲ្យជីវិតរបស់ខ្ញុំទៅជាជីវិតមួយដែលណែនាំឲ្យពិភពរបស់ខ្ញុំទៅជាពិភពថ្មី?**

ថ្ងៃនេះយើងអធិដ្ឋានសម្រាប់យុវជនយុវនារីទាំងអស់ យើងអធិដ្ឋានសម្រាប់លោកបូជាចារ្យ បងប្រុសបងស្រី បងប្អូនគ្រីស្តបរិស័ទទាំងអស់ ដែលបានយកចិត្តទុកដាក់បម្រើព្រះសហគមន៍នៅក្នុងសេចក្តីស្រឡាញ់ពីមួយថ្ងៃទីមួយថ្ងៃ ដោយសង្ឃឹមថាយើងនឹងមានគ្រូគង្វាលដ៏សប្បុរសយ៉ាងច្រើនថែមទៀត ដោយសារចំការរបស់យើងធំណាស់ យើងធ្វើដូចម្តេចដើម្បីឲ្យចំការរបស់យើងមានទាំងកម្មករ មានទាំងអ្នកច្រូត ដើម្បីឲ្យជីវិតរបស់យើងទៅជាជីវិតពិសេសសម្រាប់មនុស្សទាំងឡាយ ដោយដឹងថាពិតមែនយើងជាមនុស្សសាមញ្ញធម្មតា ប៉ុន្តែយើងជាមនុស្សពិសេសអស្ចារ្យ ដោយសារព្រះជាម្ចាស់បានជ្រើសរើសយើង ព្រះជាម្ចាស់ស្រឡាញ់យើង និងព្រះជាម្ចាស់ចាត់យើងឲ្យទៅជានិច្ច។ អាម៉ែន។